រាជបណ្ឌិត្យសភាកម្ពុជា

# វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## - ភាគទី ២ -




អត្ថបទចងក្រងដោយៈ លោកស្រី ស៊ន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

-២០១៩-

# វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១ (ភាគទី ២)


## អត្ថបទចងក្រងដោយៈ លោកស្រី ស៊ិន ច័ន្ទអមរា

## មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា


### ៣.១-ការចាប់ផ្តើមកងទ័ពនៅកម្ពុជា

«ក្រុមរក្សាស្រុក»(Garde Indigène) ពិតប្រាកដបានចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩០៤ បន្ទាប់ពីមានរាជប្រកាសចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩០៣ ដែលកំណត់អំពីរបៀបរើស«ទាហានរក្សាស្រុក»(Milicien)។ ភូមិនីមួយៗត្រូវផ្តល់ទាហានរក្សាស្រុកម្នាក់ សម្រាប់ប្រជាជន៨០នាក់ ត្រូវផ្តល់ចំនួន២នាក់ សម្រាប់ប្រជាជន ពី៨០ទៅ១៣០នាក់ ត្រូវផ្តល់៣នាក់ សម្រាប់ប្រជាជនពី១៣១ទៅ១៨០នាក់ និង ត្រូវផ្តល់ចំនួន៤នាក់ សម្រាប់ប្រជាជនពី១៨១ទៅ២៣០នាក់។ ព្រះរាជប្រកាសនោះបានកំណត់ឱ្យជ្រើសរើសឱ្យអស់ពីលទ្ធភាពនូវ មនុស្សប្រុសពោះម៉ាយនិងនៅកំលោះពីអាយុ១៨ទៅ៣៥ឆ្នាំ ប៉ុន្តែបើមិនគ្រប់ចំនួន គេត្រូវជ្រើសរើសមនុស្សប្រុស ដែលមានគ្រួសារ។ រយៈពេលបំពេញការងារគឺ២ឆ្នាំ ដោយមានលទ្ធភាពឱ្យបន្តទៅ២ឆ្នាំទៀត[1]។

ក្រុមរក្សាស្រុក មានភារកិច្ចរក្សាសណ្តាប់ធ្នាប់សង្គមនៅគ្រប់ខេត្ត។ ខេត្តនីមួយៗត្រូវជ្រើសរើស«ក្រុមពិជ័យសង្គ្រាម» មួយវរសេនាតូច ដើម្បីធ្វើអន្តរាគមន៍ក្នុងសកម្មភាពយោធាដូចជានៅក្នុងសន្តិការូបនីយកម្មខេត្តបាត់ដំបងមុនឆ្នាំ១៩១០ជាដើម[2]។ ក្រុមរក្សាស្រុកមានចំនួនចន្លោះពី១.៥០០នាក់(១៩១២-១៩១៥) និង ២.២០០-២.៤០០នាក់(១៩១៦-១៩២០)។ ចំណែកក្រុមពិជ័យសង្គ្រាមជាជនជាតិខ្មែរមានចំនួន១.៣៥០នាក់ និង រើសបន្ថែម៥០០នាក់ទៀតពីខែមករា ឆ្នាំ១៩១៦ ទៅ ខែមករា ឆ្នាំ១៩១៧ ដើម្បីចេញទៅច្បាំងនៅទ្វីបអឺរ៉ុប។



ទាហានស្ម័គ្រចិត្តខ្មែរ ថតនៅវត្តភ្នំ មុនពេលចេញដំណើរទៅប្រទេសបារាំង (ឆ្នាំ១៩១៦)

---

[1] Alain Forest, ប្រទេសកម្ពុជានិងអាណានិគមកម្មបារាំង, ប្រវត្តិនៃអាណានិគមកម្មមួយដែលគ្មានការប៉ះទង្គិច (១៨៩៧-១៩២០), Editions L'Harmattan, ១៩៨០, ទំព័រ១៣៦។

[2] តាមព្រះរាជប្រកាសចុះថ្ងៃទី១៦កុម្ភៈ១៩១២ រយៈពេលបំពេញការងាររបស់ក្រុមរក្សាស្រុកគឺ៣ឆ្នាំ។ អ្នកចាប់ឆ្នោតបានលេខដំបូងត្រូវឱ្យចូលក្នុងក្រុមពិជ័យសង្គ្រាម ចំណែកអ្នកចាប់ឆ្នោតបានលេខក្រោយត្រូវឱ្យចូលក្នុងក្រុមរក្សាស្រុក។

នៅក្នុងនិក្ខេបបទថ្នាក់បណ្ឌិតដែលមានចំណងជើងថា "ប្រទេសកម្ពុជានិងអាណានិគមកម្មបារាំង, ប្រវត្តិនៃអាណានិគមកម្មមួយដែលគ្មានការប៉ះទង្គិច" នោះ លោក Alain Forest បានសរសេរបន្តថា ការអំពាវនាវជ្រើសរើសទាហានស្ម័គ្រចិត្តទៅច្បាំងនៅប្រទេសបារាំង បានជួបនឹងការមិនអើពើជាទូទៅ ទោះបីមានការឃោសនាយ៉ាងខ្លាំងក្លាក៏ដោយ។ សេចក្តីប្រកាសត្រូវគេបិទផ្សាយនៅគ្រប់ៗភូមិ ដោយរៀបរាប់ប្រាប់អំពីផលប្រយោជន៍ដែលត្រូវផ្តល់ឱ្យដល់អ្នកស្ម័គ្រចិត្តដូចជា ការឱ្យរួចពន្ធខ្លួននៅឆ្នាំ១៩១៦ ការផ្តល់ប្រាក់ឧបត្ថម្ភ២០០ហ្រ្វង់នៅពេលស្ម័គ្រចិត្ត ការផ្តល់ប្រាក់៣រៀលក្នុង១ខែសម្រាប់គ្រួសារ និងការឧបត្ថម្ភប្រាក់១២០រៀលនៅពេលស្លាប់។ ៣ខែបន្ទាប់ពីការខិតខំជ្រើសរើស គឺនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩១៦ គេរើសបានចំនួន ២.២៩៥នាក់ ដែលនៅក្នុងនោះមនុស្ស៥០៨នាក់ ត្រូវបានគេបញ្ជូនទៅវិញព្រោះមិនស្ម័គ្រចិត្ត ស្ថិតនៅក្រោមការបង្ខិតបង្ខំពីពួកមន្ត្រី។ មនុស្សដែលនៅសល់ចំនួន១.០០៨នាក់ត្រូវបានទទួលស្គាល់ថាអាចបម្រើកងទ័ពបាន។ ទោះជាយ៉ាងនេះក្តីក៏មានអ្នកស្លាប់២០នាក់ដោយជំងឺហើមសួត បណ្តាលមកពីការហ្វឹកហាត់ដោយបង្ខំ កន្លែងស្នាក់នៅ និងចំណីអាហារមិនសមស្រប និងមនុស្ស៣៤០នាក់ទៀតបានរត់ចោល[3]។

សកម្មភាពជ្រើសរើសអ្នកស្ម័គ្រចិត្តទៅច្បាំងនៅប្រទេសបារាំងនោះ ក៏មានប្រភពមួយទៀតជា «បណ្ណសារ» (Archive) (ឯកសារប្រភពទី១) គឺលិខិតរបស់ឧកញ៉ាវាំង (រដ្ឋមន្ត្រីព្រះបរមរាជវាំង) ជូនទៅលោករេស៊ីដង់ជាន់ខ្ពស់បារាំង ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩១៦។ តាមលិខិតនោះ ព្រះបាទស៊ីសុវត្ថិបានយាងទៅជ្រើសរើសអ្នកស្ម័គ្រចិត្តនៅតាមខេត្តចំនួន២លើក ដើម្បីធ្វើជាក្រុមយុទ្ធនា និងជាង[4] ក្នុងរាជការក្រុងបារាំងសែសសម្រាប់សង្គ្រាមលោកលើកទី១។ ព្រះរាជដំណើរនេះមានរយៈពេលសរុប១៦ថ្ងៃៈ លើកទី១ចំនួន២ថ្ងៃ និងលើកទី២ចំនួន១៤ថ្ងៃ ដែលមានខ្លឹមសារដើមនិងការកែសម្រួលមួយចំនួនដូចខាងក្រោម[5]។

**ក-ព្រះរាជដំណើរលើកទី១**

ព្រះអង្គបានយាងចេញពីក្រុងភ្នំពេញនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩១៦ ទៅដល់ព្រែកបាណាម ខេត្តបាភ្នំ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩១៦ វេលាម៉ោង២រសៀលដែលនៅសល់តែ១ម៉ោងទៀតនឹងដល់ទីរួមខេត្តព្រៃវែង។ លោកឧកញ៉ាវាំងបានទទួលតេឡេក្រាម[6] ពីលោករេស៊ីដង់ជាន់ខ្ពស់លេខ១១២ ចុះថ្ងៃដដែលដើម្បីក្រាបបង្គំទូលព្រះអង្គសូមឱ្យបង្អង់ព្រះរាជដំណើរ ដោយសារលោកអគ្គទេសាភិបាល[7] នឹង

[3] Alain Forest, ប្រទេសកម្ពុជានិងអាណានិគមកម្មបារាំង, ប្រវត្តិនៃអាណានិគមកម្មមួយដែលគ្មានការប៉ះទង្គិច (១៨៩៧-១៩២០), Editions L'Harmattan, ១៩៨០, ទំព័រ១៣៨-១៣៩។

[4] ក្រុមយុទ្ធនានិងជាង គឺទាហានប្រយុទ្ធនិងទាហានជាង។

[5] ចុម្លាយ ឧកញ៉ាវាំងវរៈវៀងជ្វៃ គណៈរដ្ឋមន្ត្រី លេខ៦២ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩១៦។

[6] ពាក្យបារាំងថា Télégramme គឺទូរលេខជាសំបុត្រទាក់ទងគ្នាតាមប្រៃសណីយ៍ឬសំបុត្រខ្សែលួស។

[7] Gouverneur Général គឺលោកអគ្គទេសាភិបាលឥណ្ឌូចិនដែលគ្រប់គ្រងលើរដ្ឋទាំង៥ គឺកូសាំងស៊ីន, កម្ពុជា, អណ្ណាម, តុងកឹង និងឡាវ។

អញ្ជើញមកដល់ក្រុងភ្នំពេញនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩១៦។ ក្នុងវេលាព្រឹកនោះព្រះអង្គក៏បានទ្រង់យាង វិលមកដល់ក្រុងភ្នំពេញវិញក្នុងថ្ងៃទី២៤ ខែកុម្ភៈ វេលាអាធ្រាត្រ។

ក្នុងព្រះរាជដំណើរជ្រើសរើសអ្នកស្ម័គ្រចិត្តលើកទី១នេះ មានព្រះរាជបុត្រា៤អង្គ របស់ព្រះបាទស៊ីសុវត្ថិ គឺព្រះអង្គម្ចាស់មុនីវង្ស, ខណារ៉ាក់, សុភានុវង្ស និងវង្គត់[8] ព្រមទាំងព្រះអង្គម្ចាស់ និងឧកញ៉ាមួយចំនួនទៀតតាមហែផងដែរ។

**ខ-ព្រះរាជដំណើរលើកទី២**

ព្រះអង្គបានយាងទៅកាន់ទីរួមខេត្តព្រៃវែងម្តងទៀតដោយមានក្រុមតាមហែព្រះអង្គដដែលដូចព្រះរាជដំណើរលើកទី១ដែរ ប៉ុន្តែព្រះអង្គម្ចាស់វង្គត់មិនបានចូលរួមទេ។ ព្រះបាទស៊ីសុវត្ថិដែលអមព្រះរាជដំណើរដោយក្សត្រាក្សត្រី និងមន្ត្រីនានានោះ បានចេញពីក្រុងភ្នំពេញនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ១៩១៦ វេលាម៉ោង១១កន្លះយប់ដោយព្រះទីនាំងកប៉ាល់(ឈ្មោះអម្រឹតវង្សី), សាលុព្វ[9](ឈ្មោះឥន្ទ្រីសំបូរ) និងវេដេត[10]។ ក្នុងព្រះរាជដំណើរពីបាណាមខេត្តបាភ្នំទៅកាន់ព្រៃវែងទឹករាក់ព្រះអង្គប្រថាប់លើព្រះទីនាំងទូកធំ-តូច ទាំងអស់៧ ដោយមានកប៉ាល់តូចៗ សណ្តោងព្រមទាំងមានអ្នកតាមហែផងនោះបានមកដល់ទីរួមខេត្តព្រៃវែងនៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩១៦វេលាម៉ោង១២និង២០នាទី។ ទ្រង់ប្រថាប់ក្នុងព្រះទីនាំងទូកចតនៅកំពុងជំនួញព្រៃវែងហើយបានគិតអំពីការជ្រើសរើសអ្នកស្ម័គ្រចិត្តនៅទីនេះ ដោយជ្រើសរើសក្នុងបណ្តាប្រជាជនទាំង៨ខេត្តរួមមាន៖

- ៥ខេត្តនៅក្រោមឱវាទ "ទីរេស៊ីដង់" ព្រៃវែង គឺខេត្តបាភ្នំ ខេត្តព្រៃវែង ខេត្តពារាំង ខេត្តស៊ីធរកណ្តាល និងខេត្តល្វាឯម។
- ៣ខេត្តនៅក្រោមឱវាទ"ទីប៉ុស្តិ៍រាជការ" ស្វាយរៀង គឺខេត្តរំដួល ខេត្តស្វាយទាប និងខេត្តរមាសហែក។




«ទីរេស៊ីដង់»(Circonscription résidentielle) គឺដែនដីរដ្ឋបាលថ្នាក់ក្រោមជាតិដែលគ្រប់គ្រងដោយ«ចៅហ្វាយខេត្តបារាំង»។ «ខេត្តខ្មែរ»មុនកំណែទម្រង់រដ្ឋបាលឆ្នាំ១៩២១ ដែលនៅក្រោមឱវាទទីរេស៊ីដង់នោះ ត្រូវបានគ្រប់គ្រងដោយ

---

[8] ស៊ន សំណាង, ការវិវត្តនៃសង្គមកម្ពុជានៅចន្លោះសង្គ្រាមលោកទាំង២ (១៩១៩-១៩៣៩), និក្ខេបបទថ្នាក់បណ្ឌិតប្រវត្តិវិទ្យា សាកលវិទ្យាល័យបារីស៧, ឆ្នាំ១៩៩៥, ទំព័រ៩៤ (ព្រះបាទស៊ីសុវត្ថិមានព្រះរាជបុត្រ១អង្គទៀតឈ្មោះដួងលក្ខិណា)។

[9] សាលុព្វ (Chaloupe) ជាកប៉ាល់ឬកាណូតធំល្បឿនដោយចែវឬបើកក្តោង។

[10] វេដេត (Vedette) ជានាវាចម្បាំងខ្នាតតូចសម្រាប់យាមល្បាត។

«ចៅហ្វាយស្រុកខ្មែរ»។ ឧទាហរណ៍ ចៅហ្វាយស្រុកខេត្តបាត់ដំបង, ចៅហ្វាយស្រុកខេត្តពារាំង។




ទីប៉ុស្តិ៍រាជការ (Poste Administratif) គឺជាដែនដីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលគ្រប់គ្រងដោយ «មន្ត្រីរដ្ឋបាលប្រតិភូ» (Administrateur Délégué) បារាំង នៅពេលដែលដែនដីនោះមិនទាន់ក្លាយជាទីរស៊ីដង់នៅឡើយ ប៉ុន្តែគ្រប់គ្រងដល់ទៅ៣ខេត្ត ដូចបង្ហាញខាងលើនេះ។

ក្នុងព្រះរាជដំណើរមកដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩១៦នេះ គឺបានចំនួន១០ថ្ងៃ ហើយចំនួនអ្នកស្ម័គ្រចិត្តដែលជ្រើសរើសបានសរុបទាំងអស់៥០៦នាក់ ដោយពុំមានអ្នកស្ម័គ្រចិត្តមកពីខេត្តល្វាឯមនោះទេ។ អ្នកស្ម័គ្រចិត្តដែលជ្រើសរើសបានទាំងនោះត្រូវបានបញ្ជូនមកភ្នំពេញដើម្បីទទួលការត្រួតពិនិត្យ។ អ្នកខ្លះត្រូវគេជ្រើសរើសយក ដោយសារមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចធ្វើជារាជការបាន ចំណែកអ្នកខ្លះទៀតត្រូវគេបញ្ជូនឱ្យត្រឡប់ទៅវិញ ពីព្រោះពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ រីឯអ្នកខ្លះទៀតពេលមកដល់ក្រុងភ្នំពេញក៏ផ្លាស់ប្តូរគំនិតថាមិនធ្វើរាជការវិញ។ ដោយសារតែមូលហេតុ ខាងលើនេះហើយបានជាព្រះបាទស៊ីសុវត្ថិបញ្ជាក់ទៅចៅហ្វាយស្រុកនៃខេត្តទាំង៨ខាងលើ(ក្នុងទីរួមខេត្តរេស៊ីដង់ព្រៃវែង និងទាំងប៉ុស្តិ៍រាជការស្វាយរៀង) ឱ្យជ្រើសរើសអ្នកស្ម័គ្រចិត្តដែលមានគ្រប់លក្ខណៈសម្បត្តិឱ្យហើយ ឱ្យបានចំនួន៥០០ឬ៦០០នាក់(ដោយមិនបាច់ជ្រើសរើសជាលើកទី២នៅភ្នំពេញទៀតទេ)។

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩១៦ ទូរលេខរបស់ឧកញ៉ាវាំង លេខ៣៧ បានឱ្យដឹងថា ព្រះអង្គបានយាងពីបាណាមមកដល់ភូមិកោះកែវខេត្តល្វាឯម នៅម៉ោង៦ល្ងាច។ ដោយព្រះអង្គមិនសព្វព្រះទ័យគង់នៅទីនោះព្រះអង្គក៏យាងហួសមកចតព្រះទីនាំងកប៉ាល់ ទូក នៅភូមិទឹកឃ្លាំង(ទីតាំងសាលាខេត្តល្វាឯម) នៅម៉ោង៨យប់។

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩១៦ ពីម៉ោង៥រសៀល ចៅហ្វាយស្រុកខេត្តល្វាឯមបានរៀបទទួលព្រះអង្គដើម្បីជួបជុំនឹងព្រះសង្ឃ ក្រមការ អ្នកស្រុក ដើម្បីពន្យល់អំពីមូលហេតុនៃការជ្រើសរើសអ្នកស្ម័គ្រចិត្តនៅទីនោះ។ ក្នុងពេលនោះដែរ អ្នកស្រុកមកថ្វាយបង្គំគាល់មិនទាន់គ្រប់ឃុំនៅឡើយ ដូច្នេះព្រះអង្គទ្រង់ប្រថាប់នៅភូមិទឹកឃ្លាំងចាំទទួលរាស្ត្រនៅព្រឹកស្អែកបន្តទៀត។

នៅវេលាម៉ោង៧ព្រឹក ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩១៦ ព្រះអង្គម្ចាស់មុនីវង្សនិងលោកឧកញ៉ាវាំងបានធ្វើជាព្រះរាជតំណាងក្នុងការជួបជាមួយបណ្តារាស្ត្រហើយបានបញ្ចុះបញ្ចូលរាស្ត្រទាំងនោះឱ្យស្ម័គ្រ

ចិត្តធ្វើរាជការ ក្នុងពេលនោះក៏ជ្រើសរើសបានអ្នកស្ម័គ្រចិត្តចំនួនតែ១០នាក់ដែលចូលធ្វើជាជាង ដោយសារតែអ្នកស្រុកខេត្តល្វាឯមមួយចំនួនបានចូលក្នុងក្រុងភ្នំពេញដោយខ្លួនឯងដើម្បីស្ម័គ្រធ្វើរាជការរួចហើយ។ ឯការជ្រើសរើសអ្នកស្ម័គ្រចិត្តក្នុងខេត្តនេះតទៅទៀត ព្រះអង្គក៏បានដាក់បញ្ញត្តិទៅចៅហ្វាយស្រុកនិងក្រមការខេត្ត-ឃុំ ឱ្យយកចិត្តទុកដាក់នឹងបន្តជ្រើសរើសឱ្យបានខ្លះទៀត។ រហូតមកដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩១៦ វេលាម៉ោង៩ព្រឹក ព្រះអង្គជ្រើសរើសបានអ្នកស្ម័គ្រចិត្តសរុបចំនួន៥១៦នាក់ ក្នុងទីរួមខេត្តព្រៃវែង។

ព្រះបាទស៊ីសុវត្ថិ បានយាងចេញពីភូមិទឹកឃ្លាំងនៅវេលាម៉ោង៩កន្លះ មកដល់ក្រុងភ្នំពេញនៅម៉ោង១២ថ្ងៃត្រង់។

(សូមរង់ចាំអានភាគទី៣ ជាបន្តនៅសប្តាហ៍ក្រោយ)